# ស្នួល/កែវសីមា/អូររាំង A1, A2, A3 & A4i



**ខេត្ត** : មណ្ឌលគីរី និង ក្រចេះ

**ស្រុក** : កែវសីមា អូររាំង និង ស្នួល

**ផ្ទៃដី ( ហិកតា)** : ២៩៧.៨៤៣

**រយៈកំពស់ ( ម៉ែត្រ)** : ០ ដល់ ១.០៧០

**កូអរដោនេចំណុចកណ្តាល** : ១២° ១៥´ ជ ១០៧° ០២´ ក

## ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ ស្ថិតនៅប៉ែកខាងត្បូងខេត្តមណ្ឌលគីរី និង ខេត្តក្រចេះ ដែលគ្របដណ្តប់ដោយព្រៃស្រោង និង ព្រៃពាក់កណ្តាលស្រោង ចាប់ពីដែនជំរកសត្វព្រៃស្នួលប៉ែកនិរតីរហូតដល់ដែនជំរកសត្វព្រៃភ្នំណាមលាប៉ែកឥសាន ។ តំបន់ចន្លោះរវាងដែនជំរកទាំងពីរនេះភាគច្រើនស្ថិតនៅក្នុងតំបន់ព្រៃសម្បទានរបស់ក្រុមហ៊ុនសាមលីញអ៊ិនធីណាសូណាល់ ។ តំបន់នេះបច្ចុប្បន្ន ក៏ត្រូវបានគ្រប់គ្រងជាតំបន់អភិរក្សជីវៈចំរុះក្នុងប្រព័ន្ធព្រៃសម្បទាន ។ រុក្ខជាតិដុះក្នុងតំបន់ IBA នេះ មានលក្ខណៈជាព្រៃស្រោង និង ព្រៃពាក់កណ្តាលស្រោងដុះនៅលើភ្នំតូចៗ ហើយមានលំដាប់ថ្នាក់ឈានទៅជាព្រៃរបោះនៅប៉ែកនិរតី ប្រភេទរុក្ខជាតិគ្របដណ្តប់លើសលប់ គឺព្រៃពាក់កណ្តាលស្រោង ដែលមានរចនាសម្ព័ន្ធខុសគ្នាយ៉ាងខ្លាំងមានចាប់ព្រៃស្រោងដែលមានវល្លិ៍ប្រយោង ដើមរិត (ដើមខ្នែង) វល្លិ៍ផ្តៅ និង បន្ទាប់មកមានតំបន់វាលស្រឡះនៅស្រទាប់ក្រោម ។ នៅក្នុងដែនជំរកសត្វព្រៃស្នួល ស្មៅដុះត្រង់កន្លែងទំនាបៗខ្លះ ជាពិសេសត្រពាំងត្រូវបានកាប់ឆ្ការ ។

តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវថ្មីៗនេះបញ្ជាក់ថា តំបន់ IBA នេះ បានទ្រទ្រង់សត្វស្លាបបីប្រភេទដែលមានដែនកំណត់ ដែលគេបានរកឃើញក្នុងតំបន់ទំនាបៗនៃប្រទេសកម្ពុជា និង តំបន់ភាគខាងត្បូងប្រទេសវៀតណាមរួមមាន ប្រភេទទទាទ្រូងលឿង មាន់ទោប្រាក់ពណ៌ប្រផេះ-បៃតង និង ចាបដូនតាមុខប្រផេះ ។ តំបន់នេះបានទ្រទ្រង់ផងដែរនូវប្រភេទទទួលរងការគំរាមកំហែង និង ជិតរងគ្រោះក្នុងពិភពលោក ដូចជាក្ងោក ទាព្រៃស្លាបស កេងកងធំ និង ស្តេចកូលីត ។ ជាចុងក្រោយ តំបន់ដែលមានរយៈកំពស់ខ្ពស់ជាងស្ថិតនៅក្នុងភ្នំណាមលា (មានកំពស់រហូតដល់១.០៧០ម៉ែត្រ) បានទ្រទ្រង់ប្រភេទសត្វរស់នៅតំបន់ខ្ពង់រាបដែលតំបន់នោះត្រូវបានសិក្សាបានតែបន្តិចបន្តួចដូចគ្នាទៅនឹងតំបន់ជំរាលទាបៗនៃខ្ពង់រាបដាឡាត់នៅប៉ែកខាងកើតដែរ ។ តំបន់ទាំងនេះទ្រទ្រង់ប្រភេទពពិចក្បាលមូលទ្រូងខ្មៅ ចកវិកក្បាលប្រផេះ និង ចាបដូនតាកំប៉ោយភ្នែកខ្មៅ ។

## ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA | |
|---|---|---|---|---|
| កេងកងធំ | Great Hornbill | *Buceros bicornis* | A1 | |
| ក្ងោក | Green Peafowl | *Pavo muticus* | A1 | |
| ចាបដូនតាមុខប្រផេះ | Grey-faced Tit Babbler | *Macronous kelleyi* | | A2 |
| ចកវិកក្បាលប្រផេះ | White-cheeked Laughingthrush | *Garrulax vassali* | | A2 |
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 | |
| ទទាទ្រូងលឿង | Orange-necked Partridge | *Arborophila davidi* | A1 | A2 |

| | | | | |
|---|---|---|---|---|
| ទាព្រៃស្លាបស | White-winged Duck | *Cairina scutulata* | A1 | |
| មាន់ទោព្រាក់ពណ៌ប្រផេះ-បៃតង | Germain's Peacock Pheasant | *Polyplectron germaini* | A1 | A2 |
| ស្ដេចកូលីត | Siamese Fireback | *Lophura diardi* | A1 | |
| អកត្រីក្បាលប្រផេះ | Grey-headed Fish Eagle | *Ichthyophaga ichthyaetus* | A1 | |

**ប្រភេទសត្វប្រមូលផ្ដុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាប១០ប្រភេទរស់នៅក្នុងប្រភេទព្រៃតំបន់ភ្នំខ្ពស់ៗ ប្រាំពីរប្រភេទរស់នៅក្នុងប្រភេទព្រៃស្រោង និង មួយប្រភេទរស់ក្នុងប្រភេទព្រៃរបោះ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទថនិកសត្វទទួលរងការគំរាមកំហែងពិភពលោក**

រញ៉ៅប្រផេះ រញ៉ៅភ្លើង ស្វាព្រោស ស្វាក្ដាម ស្វាអង្កត់ ស្វាព្រាម ស្វាក្រវាត់ និង ទោចថ្នាល់លឿង ។

**ដំរី និង ពពួកក្រចកជំពាមទទួលរងការគំរាមកំហែងពិភពលោក**

ដំរី ខ្ទីង ទន្សោង និង កែះ ។

**ប្រភេទអណ្ដើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក**

អណ្ដើកបិទមុខស្នូកខ្មៅ អណ្ដើកព្រិច អណ្ដើកតឹកកាល់បន្លាមួយ និង កន្ធាយអាស៊ី ។

**ការគំរាមកំហែងលើជីវៈចំរុះ**

ការគំរាមកំហែងដែលកើតមានក្នុងតំបន់ IBA នេះ គឺការប្រមាញ់ដោយកាំភ្លើង និង អន្ទាក់ ។ ការប្រមាញ់បានផ្ដោតលើក្ងោក ដោយប្រភេទនេះមានតំលៃផ្នែកពាណិជ្ជកម្ម ។ បច្ចុប្បន្ន កំរិតការបរបាញ់កើតមានក្នុងតំបន់បានថយចុះដោយសារលទ្ធផលនៃសកម្មភាពអភិរក្ស ។ ការគំរាមកំហែងចំបងមួយទៀត គឺការកាប់ឈើ ។ ទោះជាមានការកាប់ឈើស្របច្បាប់នៅក្នុងតំបន់ជាក់លាក់ក៏ដោយ ក៏ក្នុងពេលថ្មីៗនេះសកម្មភាពនៃការកាប់ឈើខុសច្បាប់នៅតែកើតឡើង ហើយតំបន់នេះភាគច្រើនត្រូវបានគេកាប់តាំងពីអតីតកាល ដែលកន្លែងខ្លះទទួលរងការកាប់ធ្ងន់ធរនាំឱ្យតំបន់នោះមានការហូរច្រោះ ។ ដីមានជីជាតិល្អសម្រាប់ដំណាំ កសិកម្មក្នុងតំបន់នេះទាំងមូល ។ បច្ចុប្បន្ន មានការរានដីព្រៃសម្រាប់ធ្វើកសិកម្ម និង ក្នុងពេលអនាគតអត្រានៃការរានដីអាចនឹងកើនឡើង ។

**អនុសាសន៍**

ការអនុវត្តន៏ច្បាប់ និង សកម្មភាពល្បាតនាពេលបច្ចុប្បន្ននៅក្នុងតំបន់ស្ទួលនៃអភិរក្សជីវៈចំរុះសីមា ដោយផ្ដោតលើការប្រមាញ់ និង ការធ្វើពាណិជ្ជកម្មប្រភេទសត្វព្រៃសំខាន់ៗ គួរតែពង្រីកឱ្យបានគ្រប់ទីកន្លែងក្នុងតំបន់នេះ ។ ការងារនេះគួរតែរួមបញ្ចូលសត្តរក្សដែលល្បាតនៅក្នុងឧទ្យានជាតិសត្វព្រៃស្ទួល និង ភ្នំណាមលា ។ ការដាក់អន្ទាក់ និង ការប្រមាញ់គួរតែត្រូវត្រួតពិនិត្យឱ្យបានតឹងរឹងបំផុត ។

ដោយមានសេចក្ដីប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្ដីពីការអភិរក្សជីវៈចំរុះ និង ផែនការគ្រប់គ្រងព្រៃសម្បទាន តំបន់សំខាន់សត្វព្រៃក្នុងដែនព្រៃសម្បទានគួរតែកំណត់ជាតំបន់ការពារពិសេសសម្រាប់ការអភិរក្សជីវៈចំរុះ ដើម្បីធានាបានថា តំបន់ទាំងនោះមិនមានការកាប់ឈើ និង ការរំខានឡើយ ។

កម្មវិធីផ្សព្វផ្សាយចំណេះដឹងដល់សហគមន៍គួរតែផ្ដើមធ្វើ ឡើងនៅក្នុងតំបន់ទាំងមូល ដោយផ្ដោតលើសក្ដានុពលដែលពាក់ព័ន្ធជាមួយជនជាតិភាគតិច (ភ្នង) រស់នៅក្នុងដែនព្រៃនៃតំបន់អភិរក្ស និង ការផ្សព្វផ្សាយច្បាប់ថ្មីៗដល់សហគមន៍មូលដ្ឋាន

រស់នៅខាងក្រៅតំបន់ព្រៃឈើ ។ ការងារចូលរួមគួរតែស្វែងយល់សម្រាប់ការទទួលស្គាល់ និង គាំទ្រពីប្រជាពលរដ្ឋមូលដ្ឋានសម្រាប់តំបន់ការពារពិសេសនេះ និង ការកាត់បន្ថយនូវសកម្មភាពប្រមាញ់ទាំងឡាយ ។

ការវាយតំលៃពិស្តារនៃការបរបាញ់ និង ការធ្វើពាណិជ្ជកម្មនៅក្នុងតំបន់គួរតែអនុវត្តដោយផ្តោតលើតួនាទីសត្វរបស់ព្រៃដែលជាផ្នែកមួយនៃជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ។ សកម្មភាពគ្រប់គ្រងតាមបែបបទត្រឹមត្រូវគួរតែអនុវត្តដោយផ្អែកលើទាំងសហគមន៍មូលដ្ឋាន និង ស្ថាប័នពាក់ព័ន្ធ ។

នៅក្នុងតំបន់ព្រៃសម្បទានក៏នៅមានអនុសាសន៍សំខាន់ៗមួយចំនួនបន្ថែមទៀត ឧទាហរណ៏ការបិទផ្លូវទាំងឡាយដែលមិនចាំបាច់បន្ទាប់ពីសកម្មភាពប្រមូលផលព្រៃឈើរួចរាល់ គួរតែបញ្ចូលទៅក្នុងផែនការគ្រប់គ្រងព្រៃឈើ ។

ការសិក្សាស្រាវជ្រាវគួរតែធ្វើឡើងបន្ថែមទៀត ដើម្បីកំណត់ស្ថានភាពប្រភេទទទាទ្រូងលឿងនៅក្នុងតំបន់ ។

## ឯកសារយោង


Clements, T. (2002) *Establishing a biological baseline and monitoring in the Samling Concession*, Mondulkiri.

Davidson, P. and Goes, F. (2002) Five new species for Cambodia. *Cambodia Bird News* 9: 44-46.

Duckworth, J. W. and Hedges, S. (1998) Bird records from Cambodia in 1997, including records of sixteen species new for the country. *Forktail* 14: 29-36.

Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.

Tan Setha and Pech Bunnat (2000) *Threatened galliformes of Cambodia.* Paper presented at the International Galliformes Symposium, Kathmandu, Nepal, September 2000.

Tan Seth and Pech Bunnat (2001) The status and distribution of Green Peafowl *Pavo muticus* in southern Mondulkiri province, Cambodia. *Tragopan* 16: 20.

Tan Setha and Pech Bunnat (2001) Recent information on the status and conservation of galliformes in Cambodia. Pp. 39-44 in P. McGowan ed. *Galliformes 2000: Proceedings of the 2nd International Galliformes Symposi um*. Reading: World Pheasant Association.

Walston, J., Davidson, P. and Men Soriyun (2001) *A wildlife survey of southern Mondulkiri province, Cambodia*. Phnom Penh: Wildlife Conservation Society.